Speech by Mr. HIGUCHI Yoshihiro,
Minister/Deputy Chief of Mission, Embassy of Japan in Cambodia
At the Inauguration Ceremony
for the Project of Constructing Drainage System
in Preah Vihear Town, Preah Vihear Province
on March 11th, 2014

- H.E. Mr. Oum Mara, Governor of Preah Vihear Province,
- Mr. Sam Leang Try, Director of Preah Vihear Provincial Department of Publib Work and Transport,
- Venerable Monks,
- Distinguished guests, Ladies and Gentlemen,

It is a great honor for me to attend today's inauguration ceremony for the project of constructing drainage system in Preah Vihear Town, Preah Vihear Province, with the high presence of H.E. Mr. Oum Mara, Governor of Preah Vihear Province.

First of all, I would like to express my sincere gratitude to all the people who have contributed to the preparation and implementation of this project, and our special appreciation goes to the Preah Vihear Provincial Department of Public Work and Transport for taking an active initiative for this project and organizing this great ceremony today.

It is also my great pleasure to visit Preah Vihear Province for the first time and the delegation of the Japanese Embassy is on mission to conduct general studies on the situation of the province. In particular, We visited the Preah Vihear Temple this morning and I was very much impressed by the magnificent beauty of this UNESCO World Heritage. I sincerely hope that this province, which is one of the most remote provinces in Cambodia, will succeed in reducing poverty and develop in a sustainable fashion by tapping various resources it owns.

This project, which amounts to $105,422, aims to alleviate damages caused by annual flooding during the rainy season. The project is to rehabilitate 900m of drainpipes with 36 manholes in Kampong Pronak Commune, Preah Vihear provincial capital. With this project, over 10,000 people will benefit

from safety and sanitary environment and enjoy an easier access to the important facilities such as hospitals, provincial hall, market and so on which exist along these drainpipes.

Due to the mitigated flood levels, It is expected that local residents will no longer face difficulties of transportation. For example, grand-mothers and grand-fathers will be able to easily walk and cross roads. Mothers and fathers will be able to easily go their farms and bring their children to schools. Younger people will be able to easily drive motorcycles and bicycles.

In addition, the drainage system will not only improve the safety environment in Preah Vihear, but also enhance the town's hygiene and prevent the spread of communicable diseases. However, in order to secure the effective function of the system, the facility requires proper maintenance to avoid the clogging of rubbish and mud. I sincerely hope that the residents in the area will cooperate to properly maintain the facility.

To conclude my remarks, I sincerely hope that the drainage system, a symbol of warm friendship from the government of Japan and Japanese people, will effectively function and help reduce the burden of the local residents, and thus, the cordial and friendly relations existing between the Japanese and Cambodian people will be further strengthened.

Thank you very much for your attention.

# ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

## សុន្ទរកថារបស់លោក ហ៊ីហ្គូជិ យូស៊ីហ៊ីរ៉ូ

## ឧបទូត/អនុប្រធានបេសកកម្មទូត

## ស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុងពិធីសម្ពោធដាក់អោយដំណើរការគំរោងសាងសង់ប្រព័ន្ធប្រឡាយ-លូបង្ហូរទឹក

## នៅទីរួមខេត្តព្រះវិហារ

ថ្ងៃទី ១១ ខែមិនា ២០១៤

- សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈ គ្រប់ព្រះអង្គ
- សូមគោរព **ឯកឧត្តម អ៊ុំ ម៉ារ៉ា** អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ
- សូមគោរព **លោក សំ លាងទ្រី** ប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះវិហារ
- សូមគោរពឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោកស្រី អស់លោក

ខ្ញុំមានកិត្តិយសដ៏ធំធេងដោយបានមកចូលរួមពិធីសម្ពោធនៅថ្ងៃនេះ គំរោងសាងសង់ប្រពន្ធ័ប្រឡាយ-លូបង្ហូរទឹក នៅទីរួមខេត្តព្រះវិហារ ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុំ ម៉ារ៉ា** អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ។

ជាបឋម ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកដល់ការរៀបចំ និងការអនុវត្តគំរោងនេះ ហើយក៏សូមសម្តែងនូវការកោតសរសើរជាពិសេសចំពោះមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះវិហារដែលបានលើកឡើងនូវគំនិតផ្តួចផ្តើមយ៉ាងសកម្មសំរាប់គំរោងនេះ និងបានរៀបចំអោយមានពិធីសម្ពោធដ៏ឧឡារិកនៅថ្ងៃនេះ។

ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងផងដែរដែលបានមកធ្វើទស្សនកិច្ចនៅខេត្តព្រះវិហារជាលើកទី ១ និងដឹកនាំគណៈប្រតិភូស្ថានទូតជប៉ុនមកបំពេញបេសកកម្មសិក្សាអំពីស្ថានភាពជាទូទៅនៅក្នុងខេត្តនេះ ។ ជាពិសេសនោះយើងបានទៅទស្សនាប្រាសាទព្រះវិហារនៅព្រឹកមិញនេះ ហើយខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំង

អំពីភាពស្រស់ល្អប្រណិតនៃបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូនេះ ។ ខ្ញុំសង្ឃឹមដោយស្មោះសរថា ខេត្តនេះដែលជាខេត្តមួយនៅតំបន់ឆ្ងាយដាច់ស្រយាលជាងគេបំផុតនៅក្នុងប្រទេសកម្ពុជានោះ នឹងទទួលបាន ជោគជ័យនៅក្នុងការកាត់បន្ថយភាពក្រីក្រ ហើយនឹងធ្វើការអភិវឌ្ឍខេត្តប្រកបដោយនិរន្តរភាពដោយផ្អែកទៅលើ ធនធានធម្មជាតិជាច្រើនដែលខ្លួនមាន ។

គំរោងនេះ ដែលចំណាយអស់ទឹកប្រាក់ ១០៥ ៤២២ ដុល្លារអាមេរិកនោះ មានគោលបំណងដើម្បីកាត់បន្ថយ ការខូចខាតដែលបណ្តាលមកពីទឹកជំនន់នៅរដូវវស្សា ។ គំរោងនេះគឺដើម្បីជួសជុលប្រឡាយ-លូបង្ហូរទឹកប្រវែង ៩០០ម និងច្រកចូលទៅលូបង្ហូរទឹកចំនួន ៣៦ កន្លែងនៅក្នុងឃុំកំពង់ប្រណាក ទីរួមខេត្តព្រះវិហារ ។ ជាមួយ នឹងគំរោងនេះ ប្រជាជនជាង ១០ ០០០ នឹងទទួលបាននូវផលប្រយោជន៍ជាមួយនឹងបរិស្ថានប្រកបដោយសុវត្ថិភាព និងអនាម័យ ហើយនឹងទទួលបាននូវភាពរីករាយជាមួយនឹងការងាយស្រួលក្នុងការធ្វើដំណើរទៅកាន់កន្លែង សំខាន់ៗ ជាច្រើនដូចជាមន្ទីរពេទ្យ-សាលាខេត្ត-ផ្សារ ។ល។ ជាដើម ដែលមានទីតាំងនៅតាមផ្លូវដែលមាន ប្រឡាយ-លូទាំងនេះ ។

ជាងនេះទៅទៀតនោះ ប្រពន្ធ័ប្រឡាយ-លូនេះនឹងមិនគ្រាន់តែជួយដល់ការកែលំអធ្វើអោយប្រសើរឡើងនូវ បរិស្ថានសុវត្ថិភាពនៅក្នុងខេត្តព្រះវិហារតែប៉ុណ្ណោះទេ ប៉ុន្តែនៅបានជួយដល់ការពង្រឹងស្ថានភាពអនាម័យ នៅទីរួមខេត្ត ហើយនឹងជួយការពារការរីករាលដាលនៃជម្ងឺឆ្លងនានាផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីធានាថាប្រពន្ធ័ប្រឡាយ-លូនេះអាចដំណើរការទៅបានប្រកបដោយប្រសិទ្ធភាពនោះ កិច្ចការនេះទាមទារ អោយមានការថែទាំអោយបានត្រឹមត្រូវដើម្បីជៀសវាងនូវការកកស្ទះដោយសំរាម និងភក់ ។ ខ្ញុំសង្ឃឹម ដោយស្មោះសរថាប្រជាជនដែលរស់នៅក្នុងតំបន់នេះនឹងរួមសហការគ្នាដើម្បីថែរក្សាប្រពន្ធ័ប្រឡាយ-លូនេះ ។

ខ្ញុំសូមបញ្ចប់នូវសុន្ទរកថារបស់ខ្ញុំ ដោយសង្ឃឹមយ៉ាងស្មោះសរថាប្រពន្ធ័ប្រឡាយ-លូបង្ហូរទឹកនេះ ដែលជានិមិត្តរូប មួយនៃមិត្តភាពដ៏កក់ក្តៅពីសំណាក់រដ្ឋាភិបាល និងប្រជាជនជប៉ុននោះ នឹងដំណើរការប្រកបដោយប្រសិទ្ធភាព ហើយនឹងជួយការបន្ថយបន្ទុករបស់ប្រជាជននៅទីនេះ ហើយដោយហេតុនេះ ទំនាក់ទំនងប្រកបដោយភាពកក់ក្តៅ និងមិត្តភាពដែលមានរួចមកហើយរវាងប្រជាជនជប៉ុន និងប្រជាជនម្ពុជា នឹងត្រូវបានពង្រឹង និងពង្រីកជាបន្ត ទៅទៀត។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់លោក-អ្នក ។